# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងទេសចរណ៍**

**លេខ** ០១១ សណន

ថ្ងៃ សុក្រ ១០កើត ខែ ចេត្រ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២០

**ជម្រាបជូន**

**លោក-លោកស្រីប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត**

**កម្មវត្ថុ:** សេចក្តីណែនាំស្តីពីការអនុវត្តវិធានការបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យទេសចរណ៍។

**យោង:**
- សេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការបន្ថែមសំដៅជួយដល់វិស័យឯកជននិងកម្មករ-និយោជិតដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលជម្ងឺ ខូវីដ-១៩ (ជុំទី២)
- សេចក្តីប្រកាសព័ត៌មានស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការបន្ថែមសំដៅជួយដល់វិស័យឯកជននិងកម្មករ-និយោជិតដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលជម្ងឺ ខូវីដ-១៩ (ជុំទី៣, ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០)
- សេចក្តីណែនាំលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក-លោកស្រីប្រធាន** ជ្រាបថា អនុវត្តតាមសេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាលស្តីពីវិធានការបន្ថែមសំដៅជួយដល់វិស័យឯកជន និងកម្មករ-និយោជិត ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលជម្ងឺ ខូវីដ-១៩(ជុំទី២និងទី៣) ក្រសួងទេសចរណ៍សូមណែនាំ **លោក-លោកស្រីប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត** ចុះផ្សព្វផ្សាយ និងជំរុញជាបន្ទាន់ដល់ម្ចាស់អាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងទីភ្នាក់ងារទេសចរណ៍នូវវិធានការមួយចំនួន ដូចខាងក្រោម៖

១. ពង្រីកវិសាលភាពបន្ថែមលើការលើកលែងការបង់ពន្ធប្រចាំខែគ្រប់ប្រភេទ ចំពោះសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងទីភ្នាក់ងារទេសចរណ៍ ដែលបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ និងមានសកម្មភាពអាជីវកម្មនៅក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប ខេត្តកំពត ក្រុងបាវិត និងក្រុងប៉ោយប៉ែត សម្រាប់រយៈពេល០៣ខែ ដោយគិតចាប់ពី**ខែមីនា ដល់ឧសភាឆ្នាំ២០២០**។ អាជីវកម្មទាំងនេះនៅតែមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធអាករ និងប្រើប្រាស់ប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែម(E-VAT) ជារៀងរាល់ខែក្នុងអំឡុងពេលនៃការលើកលែងនេះ។

២. កំណត់ឱ្យអ្នកជាប់ពន្ធដូចបានចែងក្នុងចំណុចទី១ខាងលើ ដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០១៩យ៉ាងយឺតបំផុតឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០២០ ប៉ុន្តែ ប្រាក់ពន្ធត្រូវបានអនុញ្ញាតឱ្យបង់រំលស់ជារៀងរាល់ខែរហូតដល់ខែវិច្ឆិកា ឆ្នាំ២០២០។

៣. សម្របសម្រួលជាមួយម្ចាស់អគារ-ទីតាំងអាជីវកម្មឱ្យជួយសម្រួលដល់ភាគីអ្នកជួលដែលជាប្រតិបត្តិករទេសចរណ៍ដោយជៀសវាងការបញ្ឈប់កិច្ចសន្យា ឬការបណ្តេញចេញក្នុងករណីដែលអ្នកជួលមិនមានលទ្ធភាពបង់ថ្លៃសេវាជួលបានទាន់ពេលវេលា និងសូមលើកទឹកចិត្តឱ្យភាគីម្ចាស់អគារ-ទីតាំងអាជីវកម្មចរចាគ្នាជាមួយនឹងអ្នកជួលលើការពន្យាពេលសម្រាប់ការបង់ថ្លៃសេវាជួល និងការបញ្ចុះថ្លៃសេវាជួលជាយថាហេតុ។

៤. ជូនដំណឹងដល់ម្ចាស់អាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងទីភ្នាក់ងារទេសចរណ៍ក្នុងទីតាំងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត ដែលបានព្យួរ ឬនឹងត្រូវព្យួរអាជីវកម្មដាក់ពាក្យស្នើសុំព្យួរកិច្ចសន្យាការងារនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

តាមរយៈនាយកដ្ឋានអធិការកិច្ចការងារសម្រាប់សហគ្រាស និងអាជីវកម្មដែលមានទីតាំងនៅរាជធានីភ្នំពេញ ឬតាមរយៈមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសម្រាប់សហគ្រាស និងអាជីវកម្មដែលមានទីតាំងនៅតាមបណ្តាខេត្ត ដើម្បីទទួលបានប្រាក់ឧបត្ថម្ភ**៤០ដុល្លារអាមេរិកក្នុងមួយខែ** សម្រាប់រយៈពេល០២ខែពីរាជរដ្ឋាភិបាល ដោយមិនភ្ជាប់លក្ខខណ្ឌតម្រូវឱ្យកម្មករ-និយោជិតចូលរួមវគ្គបណ្តុះបណ្តាលជំនាញទន់(Soft Skills) រយៈពេលខ្លីដែលមានក្នុងវិធានការអន្តរាគមន៍ជុំទី១ និងជុំទី២នោះទេ។ សហគ្រាស និងអាជីវកម្មក្នុងវិស័យទេសចរណ៍ត្រូវរួមចំណែកតាមគោលការណ៍ស្ម័គ្រចិត្ត និងតាមលទ្ធភាពជាក់ស្តែងបន្ថែមលើអ្វីដែលរាជរដ្ឋាភិបាលនឹងផ្តល់ជូនកម្មករ-និយោជិត (ដូចមានកំណត់ក្នុងចំនុច "ក៣" និងត្រូវផ្សព្វផ្សាយបន្តដល់កម្មករ-និយោជិតបានជ្រាប ពិសេសលក្ខខណ្ឌផ្សេងៗដូចមានកំណត់ក្នុងចំនុច "ក៤" នៃសេចក្តីណែនាំលេខ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ។ លក្ខខណ្ឌចាំបាច់ ដើម្បីទទួលបានប្រាក់ ឧបត្ថម្ភពីរាជរដ្ឋាភិបាលរួមមាន៖

- ត្រូវមានការឯកភាពឱ្យព្យួរកិច្ចសន្យាការងារពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០នេះតទៅ
- កម្មករ-និយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារត្រូវតែជាកម្មករ-និយោជិត ដែលមានបណ្ណសមាជិក ប.ស.ស ឬស្ថិតក្នុងបញ្ជីបច្ចុប្បន្នភាពកម្មករ-និយោជិតដែលបានផ្តល់រួចហើយ ឬនឹងត្រូវផ្តល់ឱ្យអធិការការងារ យោងតាមស្មារតីនៃសេចក្តីជូនដំណឹងលេខ០០៩/២០ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ដោយឡែក ការផ្តល់ប្រាក់ឧបត្ថម្ភនេះមិនគ្របដណ្តប់ចំពោះកម្មករ-និយោជិតដែលបម្រើការងារឱ្យសហគ្រាស និងអាជីវកម្មដែលបានបិទ ឬនឹងបិទឈប់ដំណើរការនោះទេ ពីព្រោះការទូទាត់ផ្សេងៗសម្រាប់កម្មករ-និយោជិតនៅក្នុងករណីបិទដំណើរការអាជីវកម្មត្រូវអនុលោមតាមលក្ខខណ្ឌ និងនីតិវិធីនៃច្បាប់ស្តីពីក្ស័យធន។

៥. មិនចាំបាច់បង់ប្រាក់ភាគទានធានារ៉ាប់រងរបបហានិភ័យការងារ និងថែទាំសុខភាព(ប.ស.ស) ក្នុងអំឡុងពេលព្យួរ ឬផ្អាកដំណើរការអាជីវកម្មដោយធ្វើលិខិតស្នើសុំផ្អាកបង់ភាគទាន ប.ស.ស ទៅបេឡាជាតិសន្តិសុខសង្គម ក្រោយទទួលបានការឯកភាពឱ្យព្យួរកិច្ចសន្យាការងារពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្មករ-និយោជិតនៅតែបន្តទទួលបានតាវកាលិកផ្នែកថែទាំសុខភាពពីប.ស.ស និងប្រាក់ឧបត្ថម្ភសម្រាប់ពេលសម្រាលកូនពីរាជរដ្ឋាភិបាល ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ។

៦. ជូនដំណឹងដល់ម្ចាស់អាជីវកម្មទេសចរណ៍គ្រប់សេវា លើការអនុញ្ញាតការពន្យាពេលនៃការទូទាត់ប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ និងការទូទាត់ប្រាក់បំណាច់អតីតការងារសម្រាប់ឆ្នាំ២០២០នេះ ទៅឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក-លោកស្រីប្រធានមន្ទីរ** ជ្រាប និងអនុវត្ត តាមការគួរ។

សូម **លោក-លោកស្រីប្រធានមន្ទីរ** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការប្រចាំការ**

**និត ចន្ថា**

**<u>ចម្លងជូន៖</u>**

- សហព័ន្ធទេសចរណ៍កម្ពុជា (CTF)
- សមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា (CATA)
- សមាគមសណ្ឋាគារកម្ពុជា (CHA)
- សមាគមភោជនីយដ្ឋានកម្ពុជា (CRA)
- សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា (PATA)
- ឯកសារកាលប្បវត្តិ

**<u>ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖</u>**

០៩២ ៧៧៩ ៨៣៣

០៨៩ ៧៦៧ ៦៦៤